នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជតក |
| ដាក់ទៅ | : | អង្គជំនុំជម្រះតុលាការកំពូល |
| ថ្ងៃដាក់ | : | ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១២ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 19-Jan-2012, 09:10
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូល: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

## ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្ដឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹង សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើសំណើសុំប្ដឹងជំទាស់ចៅក្រម SILVIA CARTWRIGHT

---

**អ្នកដាក់ឯកសារ:**
សហព្រះរាជអាជ្ញា:
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**
អង្គជំនុំជម្រះតុលាការកំពូល:
ចៅក្រម គង់ ស្រីម, ប្រធាន
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម យ៉ា ណារិន
ចៅក្រម Motoo NOGUCHI
ចៅក្រម A. KLONOWIECKA-MILART
ចៅក្រម C. N. JAYASINGHE
ចៅក្រម ស៊ិន រិទ្ធ
ចៅក្រមបម្រុង Florence MUMBA

**ចម្លងជូន:**
ជនជាប់ចោទ:
នួន ជា
អៀង សារី
អៀង ធីរិទ្ធ
ខៀវ សំផន

មេធាវីការពារក្ដីជនជាប់ចោទ:
លោក សុន អរុណ
លោក Michiel PESTMAN
លោក Victor Koppe
លោក អាង ឧត្ដម

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**

ពេជ អង្គ

Elisabeth SIMONNEAU FORT

លោក Michael G.KARNAVAS

លោក ផាត់ ពៅសីុង

Diana ELLIS

លោក គង់ សំអុន

លោក Jacques VERGÈS

លោក Arthur VERCKEN

# I. សេចក្តីផ្តើម និងប្រវត្តិនីតិវិធី

១- នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១១ មេធាវីការពារក្តីរបស់ នួន ជា បានដាក់*បណ្តឹងជំទាស់បន្ទាន់ចំពោះចៅក្រម Cartwright* ("បណ្តឹងជំទាស់")[1] ស្នើសុំប្តឹងជំទាស់ចៅក្រម Cartwright ឬម្យ៉ាង វិញទៀត សុំឱ្យដកខ្លួនដោយស្ម័គ្រចិត្ត[2]។ បណ្តឹងជំទាស់នេះបានភ្ជាប់ជាឧបសម្ព័ន្ធ បានយោង និងបានដាក់បញ្ចូលនូវផ្នែកនានានៃសំណៅសំណើរបស់មេធាវីការពារក្តី អៀង សារី ដែលបានចម្លង ជូនពីមុនមានចំណងជើងថា *សំណើរបស់លោក អៀង សារី ស្នើឱ្យស៊ើបអង្កេតពាក់ព័ន្ធទៅនឹងការប្រាស្រ័យទាក់ទងជាមួយតែភាគីម្ខាង រវាងសហព្រះរាជអាជ្ញាអន្តរជាតិ លោកស្រីចៅក្រម Cartwright និង អ្នកដទៃទៀត*[3]។

២- នៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១១ មេធាវីការពារក្តីរបស់ អៀង សារី បានដាក់សំណើមួយ មានចំណងជើងថា *សំណើរបស់លោក អៀង សារី ស្នើសុំឱ្យស៊ើបអង្កេតពាក់ព័ន្ធទៅនឹងការប្រាស្រ័យទាក់ទងជាមួយតែភាគីម្ខាង រវាងសហព្រះរាជអាជ្ញាអន្តរជាតិ លោកស្រីចៅក្រម Cartwright និង អ្នកដទៃទៀត*("សំណើ")[4]។ សំណើនេះផ្អែកទៅលើភ័ស្តុតាងដូចគ្នា ដែលបានសំអាងនៅក្នុងបណ្តឹងជំទាស់។

៣- នៅថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១១ សហព្រះរាជអាជ្ញាបានដាក់ចម្លើយតបរួមទៅនឹងសំណើរបស់ នួន ជា និង អៀង សារី[5]។ សហព្រះរាជអាជ្ញាបានផ្តល់សំអាងថា បណ្តឹងជំទាស់ និងសំណើនេះគួរត្រូវបានបដិសេធចោល ពីព្រោះខកខានមិនបានលើកហេតុផលគ្រប់គ្រាន់ ដើម្បីគាំទ្រអំណះអំណាងរបស់ខ្លួនឡើយ។

---

[1] **E137/2** *បណ្តឹងជំទាស់ជាបន្ទាន់ចំពោះចៅក្រម* Cartwright, ២១ វិច្ឆិកា ២០១១ ("បណ្តឹងជំទាស់")។

[2] **E137/2** បណ្តឹងជំទាស់, កំណត់សម្គាល់*ខាងលើ* លេខ ១ ត្រង់កថាខណ្ឌទី១។

[3] **E137/2.1** *សំណើរបស់លោក អៀង សារី ស្នើឱ្យស៊ើបអង្កេតពាក់ព័ន្ធទៅនឹងការប្រាស្រ័យទាក់ទងជាមួយតែភាគីម្ខាង រវាងសហព្រះរាជអាជ្ញាអន្តរជាតិ លោកស្រីចៅក្រម* Cartwright *និង អ្នកដទៃទៀត*, ២២ វិច្ឆិកា ២០១១។

[4] **E137/3** *សំណើរបស់លោក អៀង សារី ស្នើឱ្យស៊ើបអង្កេតពាក់ព័ន្ធទៅនឹងការប្រាស្រ័យទាក់ទងជាមួយតែភាគីម្ខាង រវាងសហព្រះរាជអាជ្ញាអន្តរជាតិ លោកស្រីចៅក្រម* Cartwright *និង អ្នកដទៃទៀត*, ២៤ វិច្ឆិកា ២០១១ ("សំណើ")។ បានជូនដំណឹង ២៥ វិច្ឆិកា ២០១១។

[5] **E137/4** *ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹង ១) សំណើជាបន្ទាន់របស់ នួន ជា សុំប្តឹងជំទាស់ចៅក្រម* Cartwright, *និង២) សំណើរបស់ អៀង សារី សុំឱ្យស៊ើបអង្កេតទៅលើការប្រាស្រ័យទាក់ទងតែម្ខាង រវាងសហព្រះរាជអាជ្ញាអន្តរជាតិ, ចៅក្រម* Cartwright *និង អ្នកដទៃ*, ១ ធ្នូ ២០១១។

៤- នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូង ដែលមានចៅក្រមបំរុង Claudia Fenz អង្គុយជំនួសកន្លែងចៅក្រម Cartwright ដោយអនុលោមតាមវិធាន៣៤.៦ បានធ្វើ*សេចក្តីសម្រេចលើបណ្តឹងជំទាស់ចៅក្រម* *Silvia Cartwright*, ("សេចក្តីសម្រេច")[6]។ អង្គជំនុំជម្រះសាលាដំបូង បានកត់សម្គាល់ថា បណ្តឹងជំទាស់នេះគឺ"មានខ្លឹមសារជាបណ្តឹងជំទាស់" ហើយបានលើកឡើងថា ដូច្នេះ[7]។ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធទាំងសំណើ ទាំងបណ្តឹងជំទាស់ ដោយបានសម្រេចថា ខកខានពុំបានបំពេញកម្រិតលក្ខខណ្ឌតម្រូវស្តីពីភស្តុតាង និងពុំមានមូលដ្ឋានគ្រប់គ្រាន់[8]។

៥- នៅថ្ងៃទី៥ ខែមករា ឆ្នាំ២០១២ មេធាវីការពារក្តីរបស់ អៀង សារី បានដាក់បណ្តឹងសាទុក្ខមួយប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង("បណ្តឹងសាទុក្ខ")[9]។ បណ្តឹងសាទុក្ខនេះបានអះអាងថា ដោយការបកស្រាយពីសំណើនេះថាជាបណ្តឹងជំទាស់ ស្របតាមវិធាន៣៤ ជាជាងថាជាសំណើមួយសុំឱ្យមានការស៊ើបអង្កេត ស្របតាមវិធាន៣៥ "អង្គជំនុំជម្រះសាលាដំបូង បានរំលោភដល់កាតព្វកិច្ចរបស់ខ្លួនក្រោមរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីការបង្កើតអ.វ.ត.ក កិច្ចព្រមព្រៀង និងវិធានផ្ទៃក្នុង"[10]។ មេធាវីការពារក្តីរបស់ អៀង សារី បានចោទប្រកាន់ថា អង្គជំនុំជម្រះសាលា ដំបូងមិនត្រឹមតែបានប្រព្រឹត្តកំហុសឆ្គងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានប្រព្រឹត្តបទអាក្រក់ទៀត ពីព្រោះអង្គជំនុំជម្រះសាលាដំបូង "បានជ្រៀតជ្រែកដោយចេតនាពិតប្រាកដទៅក្នុងកិច្ចការរដ្ឋបាលតុលាការក្នុងសំណុំរឿង០០២" តាមរយៈ "ការកំណត់ខុស និងបកស្រាយខុសសំណើសុំឱ្យស៊ើបអង្កេត ដោយថាជាបណ្តឹងជំទាស់ តាមវិធាន៣៤"[11]។ មេធាវីការពារក្តីរបស់ អៀង សារី បានចោទប្រកាន់បន្ថែម

---

[6] **E137/5** *សេចក្តីសម្រេចលើបណ្តឹងជំទាស់ចៅក្រម Silvia Cartwright*, ២ ធ្នូ ២០១១។ បានជូនដំណឹង ២ ធ្នូ ២០១១។

[7] **E137/5** សេចក្តីសម្រេច, កំណត់សម្គាល់*ខាងលើ* លេខ៦ ត្រង់កថាខណ្ឌទី១២។

[8] **E137/5** សេចក្តីសម្រេច, កំណត់សម្គាល់*ខាងលើ* លេខ៦ ត្រង់កថាខណ្ឌទី១៩។

[9] **E137/5/1/1** *បណ្តឹងសាទុក្ខរបស់លោក អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើបណ្តឹងជំទាស់លោកស្រីចៅក្រម Silvia Cartwright*, ៥ មករា ២០១២។ បានជូនដំណឹង ១១ មករា ២០១២។

[10] **E137/5/1/1** បណ្តឹងសាទុក្ខ, កំណត់សម្គាល់*ខាងលើ* លេខ៩ ត្រង់កថាខណ្ឌទី៤។

[11] **E137/5/1/1** បណ្តឹងសាទុក្ខ, កំណត់សម្គាល់*ខាងលើ* លេខ៩ ត្រង់កថាខណ្ឌទី២៨។ តាមពិត តាមរយៈបណ្តឹងសាទុក្ខរបស់ខ្លួន មេធាវីការពារក្តីរបស់ អៀង សារី ទំនងជាជំរុញបណ្តឹងមួយដែលអង្គជំនុំជម្រះសាលាដំបូង*ខ្លួនឯង* (ដោយសន្មតជាមុនថារាប់ទាំងចៅក្រមបំរុង Frenz ផង ប៉ុន្តែមិនរាប់បញ្ចូលចៅក្រម Cartwright ទេ ដែលគាត់មិនបានចូលរួមនៅក្នុងសេចក្តីសម្រេចនោះ) ជាជាងប្រធានបទនៃសំណើនោះ ដែលគួរតែត្រូវបានស៊ើបអង្កេតតមាវិធាន៣៥ ដោយការចោទប្រកាន់ថា អង្គជំនុំជម្រះសាលាដំបូង "បានជ្រៀតជ្រែកដោយចេតនាពិតប្រាកដទៅក្នុងកិច្ចការរដ្ឋបាលតុលាការ"។ *សូមអានផងដែរ ដដែលដូចមុន* ត្រង់កថាខណ្ឌទី៣៩៖ "ការបដិសេធដោយចេតនារបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការស៊ើបអង្កេតពីការប្រជុំ*តែភាគីម្ខាង* ទាំងនេះ...បង្កើតបានជាការជ្រៀតជ្រែកដោយចេតនាពិតប្រាកដទៅក្នុងកិច្ចការ

ទៀតថា សេចក្តីសម្រេចជាឯកច្ឆន្ទរបស់អង្គជំនុំជម្រះសាលាដំបូង ត្រូវបានធ្វើឡើង "ដែលហាក់ដូចជាបញ្ចៀសមិនឲ្យមានការស៊ើបអង្កេត"[12]។ បណ្តឹងសាទុក្ខនេះមិនបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុស ក្នុងការសម្រេចថាចៅក្រមCartwright មិនគួរត្រូវបានប្តឹងជិតចិត្តនោះទេ"។

៦- មេធាវីការពារក្តីរបស់ នួន ជា មិនបានប្តឹងសាទុក្ខទេ។

៧- នៅក្នុងចម្លើយតបនេះ សហព្រះរាជអាជ្ញាសូមជូនសេចក្តីសន្និដ្ឋានថា អង្គជំនុំជម្រះតុលាការកំពូលគួរតែបដិសេធបណ្តឹងសាទុក្ខនេះចោល ពីព្រោះវាមិនអាចទទួលយកបានទេ ឬម្យ៉ាងវិញទៀត ពីព្រោះបណ្តឹងសាទុក្ខនេះមិនបានផ្តល់នូវបន្ទុកភ័ស្តុតាងរបស់ខ្លួនទេ។

## II. បណ្តឹងសាទុក្ខនេះមិនអាចទទួលយកបានទេ

៨- សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើបញ្ហានេះ មិនបើកផ្លូវឲ្យប្តឹងសាទុក្ខភ្លាមៗទេ។ ក្នុងការធ្វើបណ្តឹងសាទុក្ខរបស់ខ្លួន មេធាវីការពារក្តីរបស់ អៀង សារី បានអះអាងថាធ្វើតាមវិធាន

រដ្ឋបាលតុលាការ"។ *ដដែលដូចមុន* ត្រង់កថាខណ្ឌទី៤៤៖ "ការចាត់ទុកដោយខុសឆ្គងចំពោះសំណើសុំឲ្យស៊ើបអង្កេតរបស់អង្គជមនុំជម្រះសាលាដំបូង ថាជាបណ្តឹងជិតចិត្ត បង្កើតឲ្យមានជាការលេចឡើងជាការជ្រៀតជ្រែកដោយចេតនាពិតប្រាកដទៅក្នុងកិច្ចការរដ្ឋបាលតុលាការ"។ *ដដែលដូចមុន* ត្រង់កថាខណ្ឌទី៤៦៖ "តាមរយៈការកំណត់សំណើសុំឲ្យស៊ើបអង្កេតដោយមិនត្រឹមត្រូវ និងការកំណត់បទដ្ឋានកម្រិតលក្ខខណ្ឌតម្រូវនៃភ័ស្តុតាងដោយមិនត្រឹមត្រូវ អង្គជំនុំជម្រះសាលាដំបូងមានកំហុសទាំងលើអង្គហេតុ ឬបានបំពានឆន្ទានុសិទ្ធិរបស់ខ្លួន ដូច្នេះបានជ្រៀតជ្រែកដោយចេតនាពិតប្រាកដទៅក្នុងកិច្ចការរដ្ឋបាលតុលាការ"។ *ដដែលដូចមុន* ត្រង់កថាខណ្ឌទី៤៧៖ "អង្គជំនុំជម្រះសាលាដំបូងបានជ្រៀតជ្រែកដោយចេតនាពិតប្រាកដទៅក្នុងកិច្ចការរដ្ឋបាលតុលាការ ដោយខកខានមិនបានស៊ើបអង្កេតទៅលើកិច្ចប្រជុំ*តែភាគីម្ខាង* រវាងលោកស្រីចៅក្រម Cartwright, លោក Cayley និងអ្នកផ្សេងៗទៀត"។ សហព្រះរាជអាជ្ញាបដិសេធមិនឆ្លើយតបទៅនឹងអំណះអំណាងទាំងនេះទេ ដោយហេតុថាវាមិនមែនជាប្រធានបទនៃសំណើ ឬ សេចក្តីសម្រេចដំបូង។ ហេតុដូច្នេះហើយ វាជាបណ្តឹងសាទុក្ខមួយដែលមិនសមស្រប នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលទេ។ បន្ថែមលើនេះ អង្គជំនុំជម្រះតុលាការកំពូលក្នុងពេលថ្មីៗនេះបានសម្រេចថា៖ "គ្មានកំហុសអង្គច្បាប់ឬអង្គហេតុ និងគ្មានការរំលោភនូវឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងណាមួយដែលអាចបង្កើតបានជាការជ្រៀតជ្រែកដោយដឹង និងមានចេតនាទៅលើកិច្ចការរដ្ឋបាលតុលាការ ដោយយោងតាមអត្ថន័យនៃវិធាន ៣៥ នៃវិធានផ្ទៃក្នុងឡើយ"។ **E130/4/3** *សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្គាប់ឲ្យជនជាប់ចោទមានវត្តមានក្នុងសាលសវនាការ*, ១៣ មករា ២០១២, ទំព័រទី២។

[12] **E137/5/1/1** បណ្តឹងសាទុក្ខ, កំណត់សម្គាល់*ខាងលើ* លេខ៩ ត្រង់កថាខណ្ឌទី៤។ *សូមមើលផងដែរ, ដដែលដូចមុន* ត្រង់កថាខណ្ឌទី៤០ ("វាហាក់ដូចជាថា អង្គជំនុំជម្រះធ្វើបែបនេះ ក្នុងគោលបំណងគេចចេញពីការគោរពតាមវិធានផ្ទៃក្នុង និងពីការរៀបចំស៊ើបអង្កេត...")។

១០៤.១ និង ១០៤.៤។ ក្នុងការធ្វើដូច្នេះ ពួកខ្លួនបានបញ្ចូលគ្នានូវបទប្បញ្ញត្តិយុត្តាធិការរបស់អង្គជំនុំជម្រះតុលាការកំពូលលើប្រធានបទនានា តាមវិធាន១០៤.១ ជាមួយនឹងបញ្ជីប្រធានបទនានាដែលបើកផ្លូវឲ្យប្តឹងសាទុក្ខភ្លាមៗ ដូចមានរៀបរាប់នៅក្នុងវិធាន ១០៤.៤។ វិធាន ១០៤.១ មានចែងពីយុត្តាធិការរបស់អង្គជំនុំជម្រះតុលាការកំពូលលើប្រធានបទនានា ក៏ប៉ុន្តែពុំមានចែងពីមូលដ្ឋានឯករាជ្យណាមួយ សម្រាប់សេចក្តីសម្រេចបើកផ្លូវឲ្យប្តឹងសាទុក្ខភ្លាមៗទេ។ តាមការអានយ៉ាងត្រឹមត្រូវវិធាន១០៤.១ ចែងថា យុត្តាធិការរបស់អង្គជំនុំជម្រះតុលាការកំពូលលើបណ្តឹងសាទុក្ខដែលមានមូលដ្ឋាននៅលើ "ក) កំហុសលើអង្គច្បាប់ ដែលនាំឲ្យមោឃៈសាលក្រមលើអង្គសេចក្តី ឬសេចក្តីសម្រេចនោះ, ខ) កំហុសនៃអង្គហេតុដែលនាំឲ្យសាលក្រមលើអង្គសេចក្តី ឬសេចក្តីសម្រេចនោះមានភាពអយុត្តិធម៌" ហើយផងដែរ ខណៈដែលធ្វើការពិចារណាពីបញ្ហាណាមួយដែលអាចធ្វើបណ្តឹងសាទុក្ខភ្លាមៗបាន, ដូចជា "ការភ័ន្តច្រឡំដែលស្តែងចេញពីការប្រើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងដែលនាំឲ្យប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បណ្តឹងសាទុក្ខ" ក៏មានរាប់បញ្ចូលផងដែរ។ យ៉ាងណាក៏ដោយ បញ្ហានានាដែលបើកផ្លូវឲ្យប្តឹងសាទុក្ខភ្លាមៗ បានមានរៀបរាប់នៅក្នុងវិធាន១០៤.៤[13]។ គោលជំហរនេះត្រូវបានបញ្ជាក់នាពេលថ្មីៗនេះដោយអង្គជំនុំជម្រះតុលាការកំពូល[14]។ ខណៈដែលការអះអាងមិនស្ថិតនៅក្នុងប្រភេទណាមួយក្នុងចំណោមប្រភេទដែលមានចែងនៅក្នុងវិធាន១០៤.៤ទេនោះ វិធានគឺច្បាស់លាស់ណាស់ដែលថា "សេចក្តីសម្រេចផ្សេងៗទៀត អាចប្តឹងសាទុក្ខបាន តែក្នុងករណីដែលបានធ្វើឡើងស្របពេលជាមួយបណ្តឹងសាទុក្ខពីសាលក្រមលើអង្គសេចក្តី"[15]។

៩- មេធាវីការពារក្តីរបស់ អៀង សារី បានអះអាងបន្ថែមទៀតថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង គឺអាចប្តឹងសាទុក្ខបានភ្លាមៗ នៅក្រោមវិធាន១០៤.៤.ឃ[16]។ វិធាន១០៤.៤.ឃ អនុវត្តចំពោះ "សេចក្តីសម្រេចស្តីពីការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ នៅក្រោមវិធាន ៣៥.៦"។ យ៉ាងណាក៏ដោយ អង្គជំនុំជម្រះសាលាដំបូងគឺច្បាស់លាស់ណាស់ដែលថា

---

[13] **E169/1/2** *សេចក្តីសម្រេចលើបណ្តឹងសាទុក្ខដែលបានដាក់ដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្រុម២ និង ក្រុម៣ ប្រឆាំងនឹងសេចក្តីសម្រេចធ្វើឡើងដោយផ្ទាល់មាត់របស់អង្គជំនុំជម្រះសាលាដំបូង នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩*, ២៤ ធ្នូ ២០០៩ ត្រង់កថាខណ្ឌទី ៩-១២។

[14] **E130/4/3** *សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងបង្គាប់ឲ្យជនជាប់ចោទមានវត្តមានក្នុងសាលសវនាការ*, ១៣ មករា ២០១២, ទំព័រទី២។

[15] វិធាន១០៤។

[16] **E137/5/1/1** បណ្តឹងសាទុក្ខ, កំណត់សម្គាល់*ខាងលើ* លេខ៩ ត្រង់កថាខណ្ឌទី៧។

"ញត្តិរបស់ អៀង សារី មានខ្លឹមសារជាបណ្តឹងជិតចិត្ត" ហើយថា "បទប្បញ្ញត្តិដែលពាក់ព័ន្ធ គឺគួរតែវិធាន៣៤.២ នៃវិធានផ្ទៃក្នុង ទើបត្រឹមត្រូវជាង"[17]។ ជាលទ្ធផល សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង មិនមែនជាសេចក្តីសម្រេចមួយដែលធ្វើឡើង "តាមវិធាន៣៥.៦" ដូចដែលវិធាន១០៤.៤.ឃ បានតម្រូវនោះទេ ហើយហេតុដូច្នេះ គឺមិនអាចទទួលយកបានទេ។ សហព្រះរាជអាជ្ញាជូនសេចក្តីសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងគឺស្ថិតនៅក្នុងឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការបកស្រាយលើសេចក្តីសន្និដ្ឋានរបស់ អៀង សារី ថាជាសេចក្តីសម្រេចមួយដែលបានធ្វើឡើងតាមវិធាន៣៤ ដូចដែលបានថែងនៅក្នុងផ្នែកទី III ខាងក្រោមនេះ។

## III. សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង គឺស្ថិតនៅក្នុងឆន្ទានុសិទ្ធិរបស់ខ្លួន

១០- បើទុកណាជា អង្គជំនុំជម្រះតុលាការកំពូល ទទួលយកបណ្តឹងសាទុក្ខនេះក៏ដោយ ក៏វាគួរតែត្រូវបានបដិសេធចោលដែរ។ មេធាវីការពារក្តីរបស់ អៀង សារី បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសនៅក្នុងការដោះស្រាយលើសំណើរបស់មេធាវី ដោយថាវាជាបណ្តឹងជិតចិត្ត ស្របតាមវិធាន៣៤ ជាជាងថាវាជាសំណើសុំឲ្យមានការស៊ើបអង្កេត ស្របតាមវិធាន៣៥។ ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូង គឺបានស្ថិតនៅក្នុងឆន្ទានុសិទ្ធិរបស់ខ្លួនយ៉ាងពេញលេញ ក្នុងការដោះស្រាយលើសំណើដែលបានតវ៉ានេះ។ បន្ថែមលើនេះ សំណើនេះខកខានមិនបានផ្តល់នូវបន្ទុករបស់ខ្លួនទេ សូម្បីតែគេពិចារណាវាទៅតាមវិធាន៣៥ ក៏ដោយ។

### ក. វិសាលភាពនៃការពិនិត្យឡើងវិញ

១១- យុត្តិសាស្ត្ររបស់ អវតក បានសម្រេចថា "អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការអន្តរជាតិនានា មានវិសាលភាពមានកម្រិតក្នុងការពិនិត្យឡើងវិញ នៅពេលដោះស្រាយបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចឆន្ទានុសិទ្ធិយុត្តាធិការរបស់សាលាដំបូង"[18] ហើយបានអនុម័តយកតាមការសាកល្បងរបស់តុលាការ ICTY ដូចខាងក្រោមនេះ៖

[17] **E137/5** សេចក្តីសម្រេច, កំណត់សម្គាល់*ខាងលើ* លេខ៦ ត្រង់កថាខណ្ឌទី១២។

[18] **D164/4/13** *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភ័ស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម*, ១៨ វិច្ឆិកា ២០០៩ ត្រង់កថាខណ្ឌទី២៦។

[]ការអនុវត្តឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង នឹងត្រូវបានកែប្រែ បើសិនជាសេចក្តីសម្រេចដែលបានប្តឹងនោះ ត្រូវបាន (១)ផ្អែកលើការបកស្រាយដែលមិនត្រឹមត្រូវអំពីច្បាប់ដែលគ្រប់គ្រង (២) ផ្អែកលើសេចក្តីសន្និដ្ឋានលើអង្គហេតុដែលជាក់ស្តែងមិនត្រឹមត្រូវ (៣) មានភាពមិនត្រឹមត្រូវ និងមិនសមហេតុសមផលយ៉ាងខ្លាំង ដូចជាបង្កើតទៅជាការរំលោភបំពានលើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង។ ការមិនមានវត្តមានកំហុសខាងអង្គច្បាប់ ឬ មិនមានការរកឃើញកំហុសខាងអង្គហេតុណាមួយច្បាស់លាស់ វិសាលភាពនៃការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខ មានកម្រិតកំណត់៖ សូម្បីតែអង្គជំនុំជម្រះសាលាឧទ្ធរណ៍[ក៏បានសម្រេចខុសគ្នាពីអង្គជំនុំជម្រះសាលាដំបូងដែរ] សេចក្តីសម្រេចខាងក្រោមនេះ ស្ថិតនៅដដែល លុះត្រាតែសេចក្តីសម្រេចនេះមានភាពមិនសមហេតុសមផល ដូចជាបង្ខំឲ្យធ្វើជាសេចក្តីសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងបានខកខានមិនបានអនុវត្តនូវឆន្ទានុសិទ្ធិរបស់ខ្លួនដោយការពិចារណាឲ្យបានល្អិតល្អន់ទេ[19]។

១២- ក្នុងការប្រើពាក្យពេចន៍ខុសគ្នាបន្តិច អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTR បានសម្រេចស្រដៀងគ្នានេះថា "នៅពេលពិនិត្យឡើងវិញទៅលើការអនុវត្តឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង បញ្ហាគឺមិនមែននៅត្រង់ថាតើអង្គជំនុំជម្រះសាលាឧទ្ធរណ៍យល់ព្រម ឬមិនយល់ តាមសេចក្តី

[19] ឯកសារលេខ **D140/9/5** សេចក្តីសម្រេចជាសាធារណៈលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតដែលបដិសេធលើសំណើរបស់គាត់ដែលសុំឲ្យតែងតាំងអ្នកជំនាញបន្ថែមមួយរូបទៀត ដើម្បីពិនិត្យឡើងវិញលើកម្មវត្ថុរឿងនៃរបាយការណ៍របស់អ្នកជំនាញដែលបានដាក់ជូនដោយលោកស្រី *Ewa Tabeau* និងលោក *Theay Kheam*, ចុះថ្ងៃទី២៨ មិថុនា ២០១០ ត្រង់កថាខណ្ឌទី១៥-១៧, **ដែលដកស្រង់**ពីករណីរឿងក្តីរបស់ *Slobodan Milošević ទល់នឹង រដ្ឋអាជ្ញា* , សំណុំរឿងលេខ IT-02-54-AR73.7, *សេចក្តីសម្រេចលើបណ្តឹងសាទុក្ខលើករណីបន្ទាន់បង្ខំប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការចាត់តាំងមេធាវីការពារក្តី*, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ចុះថ្ងៃទី១ វិច្ឆិកា ២០០៤។ ឯកសារលេខ **D348/2/7** សេចក្តីសម្រេចជាការសម្ងាត់ លើបណ្តឹងសាទុក្ខរបស់សហមេធាវីការពារក្តីរបស់ដើមបណ្តឹងរដ្ឋប្បវេណីប្រឆាំងនឹងដីកាសម្រេចដែលទាក់ទងនឹងសាក្សីមួយរូប អំពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅមន្ទីរស-២៤ *បន្ទាប់ពីការដាក់សាឬណបន្ថែម*, ចុះថ្ងៃទី៤ សីហា ២០១០ ត្រង់កថាខណ្ឌទី៩ (ដែលដកស្រង់ខ្លឹមសារដូចគ្នាតែមួយ)។ ឯកសារលេខ **D356/2/9** *សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ នួន ជា ដែលប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតដែលបដិសេធសំណើដែលសុំការផ្តល់មតិរបស់អ្នកជំនាញទីពីរ*, ចុះថ្ងៃទី១ កក្កដា ២០១០ ត្រង់កថាខណ្ឌទី១៦-១៨ (ការដកស្រង់ខ្លឹមសារតែមួយដដែលច)។ *សូមអាន ផងដែរ ករណីរឿក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង* *Tharsisse Muvunyi*, សំនុំរឿងលេខ ICTR-00-55A-AR73, *សេក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់អយ្យការលើបញ្ហាបន្ទាន់បង្ខំ ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះទី២ ចុះថ្ងៃទី២៣ កុម្ភៈ ២០០៥*, កាលបរិច្ឆេទថ្ងៃទី១២ ឧសភា ២០០៥ ត្រង់កថាខណ្ឌទី៥ (ដកស្រង់ខ្លឹងសារដូចគ្នាដដែល)។ *សូមអាន ផងដែរ ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង* *Hormisgas Nsengimana*, សំណុំរឿងលេខ ICTR-01-69-A, សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់អយ្យការចំពោះសេចក្តីសម្រេចទាក់ទងនឹងការប្រាស្រ័យទាក់ទងគ្នាដោយមិនត្រឹមត្រូវជាមួយសាក្សីដាក់បន្ទុក, ចុះថ្ងៃទី១៦ ធ្នូ ២០១០ ត្រង់កថាខណ្ឌទី៨។

សម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនោះទេ ប៉ុន្តែនៅត្រង់ថា តើនៅក្នុងការឈានទៅដល់ការធ្វើសេចក្តីសម្រេចរបស់ខ្លួននោះ អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនដោយសមហេតុ សមផលដែរ ឬទេ?”[20]។

**ខ. ឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការសម្រេចលើសំណើសុំ ត្រូវបានតវ៉ា**

១៣- អង្គជំនុំជម្រះសាលាដំបូងស្ថិតនៅក្នុងរង្វង់ឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងការទាក់ទងនឹងការចាត់ចែងរៀបចំដំណើរការសវនាការជំនុំជម្រះក្តី ដើម្បីពិនិត្យពិចារណាអំពីថាតើការដាក់ឯកសារណាមួយ បានដាក់តាមវិធានផ្ទៃក្នុងដែលជាចំណុចផ្តោតន្លៃ្ងត្តិស្នើសុំដែរ ឬទេ ទោះបីជានៅពេលដែលភាគីអ្នកប្តឹងទាមទារឲ្យដាក់សារណានោះនៅក្រោមវិធានមួយផ្សេងទៀតវិញក៏ដោយ[21]។ ក៏ប៉ុន្តែ នៅទីនេះមេធាវីការពារក្តីរបស់ អៀង សារី មិនគ្រាន់តែបានផ្តោតទៅលើវិធាន ៣៤ នៃវិធានផ្ទៃក្នុងប៉ុណ្ណោះទេ តែថែមទាំងបានបញ្ជាក់ថា វិធាន ៣៤ នេះ គឺជា“ច្បាប់ជាធរមាន”ទៀតផង[22]។

១៤- សំណើសុំនេះ ពោរពេញទៅដោយការយោង និងការវិភាគដែលផ្អែកលើមូលដ្ឋាននៃការសាកល្បងសម្រាប់ការប្តឹងជំទាស់ដែលស្របតាមវិធាន៣៤(២)នៃវិធានផ្ទៃក្នុងដែលចែងថា៖

---

[20] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង* Tharsisse Muvunyi, *សំណុំរឿងលេខ* ICTR-00-55A-AR73, *សេចក្តីសម្រេចលើបណ្តឹងសាទុក្ខលើករណីបន្ទាន់បន្ថែ ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទី២ ចុះថ្ងៃទី២៣ កុម្ភៈ ២០០៥,* ចុះកាលបរិច្ឆេទថ្ងៃទី១២ ឧសភា ២០០៥ ត្រង់កថាខណ្ឌទី៥។ *សូមអានផងដែរ ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង* Francis Kirimi Muthaura, Uhuru Muigai Kenyatta *និង* Mohamed Hussein Ali, សំណុំរឿងលេខ ICC-01/09-02/11 OA, *សាលដីកាលើបណ្តឹងសាទុក្ខរបស់សាធារណៈរដ្ឋប្រទេសកេនយ៉ា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះទី២ ចុះថ្ងៃទី៣០ ឧសភា ២០១១ ដែលមានចំណងជើងថា: “ សាលដីកាសម្រេចលើពាក្យសុំដោយរដ្ឋាភិបាលកេនយ៉ាដែលប្រឆាំងនឹងភាពអាចទទួលយកបាននៃករណីរឿងក្តីអនុលោមតាមមាត្រា ១៩(២)(ខ) នៃលក្ខន្តិកៈ”, មតិប្រឆាំងរបស់លោកចៅក្រម* Anita Ušacka, ចុះថ្ងៃទី២០ កញ្ញា ២០១១ ត្រង់កថាខណ្ឌទី១៥ ( អង្គជំនុំជម្រះសាលាឧទ្ធរណ៍មិនបាន “ដឹកនាំធ្វើសវនាការ *ជាថ្មី* ពិនិត្យលើបណ្តឹងសាទុក្ខនោះទេ ហើយអាស្រ័យហេតុនេះ គឺមានអាចដាក់ជំនួសឆន្ទានុសិទ្ធិរបស់ខ្លួន ដោយឆន្ទានុសិទ្ធិរបស់អង្គបុរេជំនុំជម្រះឬ អង្គជំនុំជម្រះសាលាដំបូងបានឡើយ”)។

[21] *សូមអាន ឧទាហរណ៍ដូចជា ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង*Casimir Bizimungu *និងគូរកន*., សំណុំរឿងលេខ ICTR-99-50-T, *សេចក្តីសម្រេចលើញត្តិស្នើសុំរបស់* Justin Mugenzi *ដែលចោទប្រកាន់អំពីការអូសបន្លាយពេលដោយមិនត្រឹមត្រូវ និងការស្វែងរកសុំដើម្បីបំបែកកិច្ចដំណើរការនីតិវិធី,* ចុះថ្ងៃទី១៤ មិថុនា ២០០៧ ត្រង់កថាខណ្ឌទី៨។

[22] ឯកសារលេខ **E137/3** សំណើសុំ, កំណត់សំគាល់លេខ ៤ *ខាងដើម* ត្រង់ទំព័រ៦។

ភាគីអាចប្តឹងជំទាស់ចិត្តចំពោះចៅក្រមណាម្នាក់ ក្នុងករណីណាមួយដែលចៅក្រមរូបនោះមាន ឬធ្លាប់មានផលប្រយោជន៍ផ្ទាល់ខ្លួន ឬហិរញ្ញវត្ថុ ឬពាក់ព័ន្ធដែលធ្វើឱ្យប៉ះពាល់យ៉ាងពិតប្រាកដ ដល់ភាពអនាគតិរបស់ចៅក្រមរូបនោះ ឬជាសត្យានុម័តស្តែងឱ្យឃើញមានភាពលំអៀង។

ការសាកល្បងដើម្បីក្តាប់ឱ្យបានយល់ច្បាស់គ្រប់គ្រាន់ អំពីភាពលំអៀង ដើម្បីជំទាស់ចិត្តថាតើ "កាលៈទេសៈនានា នឹងនាំឱ្យអ្នកសង្កេតការណ៍ដ៏ត្រឹមត្រូវទទួលបាននូវការផ្តល់ព័ត៌មានបានត្រឹមត្រូវ ដើម្បីក្តាប់បានច្បាស់ដោយសមហេតុសមផលអំពីភាពលំអៀងនោះ"[23]។ សំណើរបស់ អៀង សារី នៅក្នុងកថាខណ្ឌទី១ បានសរសេរថា: "ការប្រាស្រ័យទាក់ទង*ដែលធ្វើឡើងដោយភាគីតែម្ខាង* រវាងចៅក្រមមួយរូប និងសហព្រះរាជអាជ្ញាមួយរូបដែលចូលរួមក្នុងរឿងក្តីតែមួយ គឺរំលោភទៅលើវិធាននៃក្រមសីលធម៌វិជ្ជាជីវៈជាធរមាន ហើយ*ដែលអាចធ្វើឱ្យមានភាពលំអៀង*ជាសត្យានុម័ត"[24]។

១៥- នៅក្នុងផ្នែកទីIII នៃសំណើដែលដាក់ចំណងជើងថា: "ច្បាប់ជាធរមាន" មេធាវីការពាររបស់ អៀង សារី បានបញ្ជាក់ច្បាស់ថា ខ្លួនធ្វើសំណើរបស់ខ្លួននេះអនុលោមតាមវិធាន៣៤ នៃវិធានផ្ទៃក្នុង[25]។ នៅក្នុងផ្នែកទីIII(ខ) ដែលដាក់ចំណងជើងថា "ការដកខ្លួន និងបណ្តឹងជំទាស់ចិត្តចៅក្រម" បានដកស្រង់ខ្លឹមសារនៃវិធាន៣៤(២)ទាំងស្រុង និងបន្តដកស្រង់ខ្លឹមសារ និងលើកសំអាងលើករណីយុត្តិសាស្ត្រដែលធ្វើការបកស្រាយអំពីបទដ្ឋាននៃការប្តឹងជំទាស់ចិត្ត[26]។ នៅក្នុងផ្នែកដែលនិយាយអំពី "ច្បាប់ជាធរមាន" *គ្មានត្រង់ណា* ដែលមេធាវីការពាររបស់ អៀង សារី បានបញ្ជាក់ ឬលើកសំអាងទៅលើវិធាន៣៥ ទាល់តែសោះ។ មេធាវីការពាររបស់ អៀង សារី បានបន្តលើកយោងទៅលើការសាកល្បងរបស់ "អ្នកសង្កេតការណ៍ឯករាជ្យ"ដូចមាននៅក្នុងកថាខណ្ឌទី២៦ និងទាញហេតុហេតុផលថា កាលៈទេសៈទាំងនេះបំពេញបានតាមលក្ខខណ្ឌនៃការសាកល្បងសម្រាប់ការប្តឹងជំទាស់ចិត្តដែលស្ថិតនៅ

[23] ឯកសារលេខ **E55/4** *សេចក្តីសម្រេចលើបណ្តឹងសុំរបស់ អៀង ធីរិទ្ធ, នួន ជា និង អៀង សារី ដែលសុំជំទាស់ចិត្តលោកចៅក្រម និល ណុន, លោកស្រីចៅក្រម* Silvia Cartwright, *លោកចៅក្រម យ៉ា សុខន* , Jean-Marc Lavergne *និង* Thou Mony, ចុះថ្ងៃទី២៣ មីនា ២០១១, កថាខណ្ឌទី១៩ ។

[24] ឯកសារលេខ **E137/3** សំណើ, កំណត់សំគាល់លេខ៤ *ខាងដើម* ត្រង់ទំព័រ១ (ការសង្កត់ន័យបន្ថែមដោយអក្សរទ្រេត)។

[25] ឯកសារលេខ **E137/3** សំណើ, កំណត់សំគាល់លេខ៤ *ខាងដើម* ត្រង់កថាខណ្ឌពីទី៦-៩។

[26] ឯកសារលេខ **E137/3** សំណើ, កំណត់សំគាល់លេខ៤ *ខាងដើម* ត្រង់កថាខណ្ឌពីទី១៧-១៩។

ក្រោមភាពលម្អៀងពិតប្រាកដ ឬនៅក្រោមបទដ្ឋានស្តីពីភាពលំអៀងដែលមាននៅក្នុងកថាខណ្ឌទី២៥ ២៧, ៣២, ៣៣ និង៣៤[27]។

១៦- អាស្រ័យហេតុនេះ ខុសគ្នាពី "ការកំណត់ខុស[] និងការបកស្រាយខុស[28]"សំណើ ការបកស្រាយរបស់អង្គជំនុំជម្រះសាលាដំបូង លើសំណើថាជាការលើកឡើងក្រោមវិធាន៣៤នៃវិធានផ្ទៃក្នុង គឺជាសមត្ថកិច្ចផ្អែកតាមការទាញហេតុផលដែលបញ្ជូនមកដោយមេធាវីការពារក្តីរបស់ អៀង សារី ខ្លួនឯង ហើយយ៉ាងហោចណាស់ ក៏អង្គជំនុំជម្រះស្ថិតនៅក្នុងរង្វង់នៃឆន្ទានុសិទ្ធិរបស់ខ្លួន ដើម្បីធ្វើការបកស្រាយដូចនេះដែរ។ លើសពីនេះទៅទៀត ដូចដែលបានពន្យល់ពីខាងលើរួចមកហើយ ក្នុងការបកស្រាយលើសំណើមួយដែលអាចអនុញ្ញាតឱ្យធ្វើបាននោះ សេចក្តីសម្រេចអនុលោមតាមវិធាន ៣៤ នៃវិធានផ្ទៃក្នុង គឺមិនមែនជាកម្មវត្ថុនៃបណ្តឹងសាទុក្ខភ្លាមៗណាមួយ នៅក្រោមវិធាន១០៤(៤)(ឃ)នោះឡើយ។

## គ. សំណើនេះក៏ខកខានមិនបានបំពេញទៅតាមសេចក្តីសន្និដ្ឋានណាមួយអនុលោមតាមវិធាន៣៥ដែរ

១៧- កាលពីដើមដំបូង សហព្រះរាជអាជ្ញាបានរំលឹកឡើងវិញថា វិធានការណ៍នានា ក្រោមវិធាន៣៥ គឺជាឆន្ទានុសិទ្ធិ ហើយអាចត្រូវបានបង្កើតឡើងដោយអង្គជំនុំជម្រះ*តាមគំនិតយល់ឃើញរបស់ខ្លួនផ្ទាល់*[29]។ ហេតុដូចនេះ ទោះបីជាមេធាវីការពារក្តីរបស់ អៀង សារី ដាក់សារណាមួយត្រឹមត្រូវតាមវិធាន៣៥ និងបានបំពេញគ្រប់តាមបន្ទុកភស្តុតាងរបស់ខ្លួនក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិរបស់ខ្លួន មិនបន្តដំណើរការស៊ើបសួរអនុលោមតាមវិធាន៣៥នៃវិធានផ្ទៃក្នុងនោះដែរ[30]។ ជាបន្ថែមពីលើនេះ អង្គជំនុំជម្រះសាលាដំបូង ដែលបានប្រឈមមុខទល់នឹងភស្តុតាងគ្រប់គ្រាន់

[27] មេធាវីការពារក្តីរបស់ អៀង សារី បន្តពោលអះអាងថានឹង "ដាក់បញ្ចូលជាមួយគ្នា[]ដោយយោងលើ" កថាខណ្ឌទាំងនេះ នៃសំណើសុំ ដែលដាក់បញ្ចូលរួមទាំង "ច្បាប់ជាធរមាន" ផង, នៅក្នុងបណ្តឹងសាទុក្ខរបស់ខ្លួន, ដែលតាមរយៈនេះ គឺលើកច្រំដែលៗនូវកំហុសរបស់ខ្លួន។ ឯកសារលេខ **E137/5/1/1** បណ្តឹងសាទុក្ខ, កំណត់សំគាល់លេខ៩ ខាងដើម, ទំព័រ១។

[28] ឯកសារលេខ **E137 5/1/1** បណ្តឹងសាទុក្ខ , កំណត់សំគាល់លេខ៩ ត្រង់កថាខណ្ឌទី១។

[29] វិធាន ៣៥ នៃវិធានផ្ទៃក្នុង មិនមានតម្រូវឱ្យដាក់សារណាទេ ហើយការប្រើ ពាក្យអនុញ្ញាត "អាច" ជាជាងការប្រើពាក្យបញ្ជា "ត្រូវ"។

[30] *សូមអាន ករណីរឿងក្តីរបស់* Léonidas Nshogoza *ទល់នឹង រដ្ឋអាជ្ញា*, សំណុំរឿងលេខICTR-07-91-AR77, សាលដីកាសម្រេចលើបណ្តឹងសាទុក្ខរបស់ Nshogoza *ចំពោះសេចក្តីសម្រេចលើការចោទប្រកាន់អំពីការប្រមាថមើលងាយ ដោយសាមាជិកនានារបស់អយ្យការ*,ចុះថ្ងៃទី៧ កក្កដា ២០១១ ត្រង់កថាខណ្ឌទី ១២ ("អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានរំឭកឡើងវិញថា អង្គជំនុំជម្រះអាចមានសិទ្ធិរកឃើញ ករណីស្តីពីការប្រមាថមើលងាយ *ដោយគ្រាន់តែឃើញមួយក្រឡេកភ្នែកដំបូង* ហើយធ្វើការកំណត់សម្រេច, ដោយស្ថិតនៅក្នុងរង្វង់ព្រំដែននៃ

នឹងបង្គាប់នៅក្នុងរង្វង់ឆន្ទានុសិទ្ធិរបស់ខ្លួន ដើម្បីឱ្យធ្វើការស៊ើបសួរអនុលោមតាមវិធាន៣៥ ទោះបីជាគ្មានការដាក់ញត្តិស្នើសុំណាមួយក្នុងរឿងនេះក៏ដោយ។ ដោយប្រឈមមុខនឹងការបង្ហាញភ័ស្តុតាងដូចគ្នាដែលមេធាវីការពារក្តីរបស់ អៀង សារី បានពឹងផ្អែកនៅក្នុងបណ្តឹងសាទុក្ខ នោះអង្គជំនុំជម្រះបានសម្រេចមិនបង្គាប់ឱ្យមានការស៊ើបអង្កេតទេ ទោះបីជាអង្គជំនុំជម្រះមានឆន្ទានុសិទ្ធិធ្វើដូច្នេះក៏ដោយ។ ជាងនេះទៀត អង្គជំនុំជម្រះបានបញ្ជាក់ទស្សនៈច្បាស់ថា ការតវ៉ារបស់មេធាវីការពារក្តី អៀង សារី គឺគ្មានខ្លឹមសារសោះ[31]។

១៨- មេធាវីការពារក្តីរបស់ អៀង សារី ខកខានមិនបានបំពេញទៅតាមបន្ទុកភ័ស្តុតាងរបស់ខ្លួនឡើយ។ ដើម្បីបំពេញបាននូវបន្ទុកភ័ស្តុតាងរបស់ខ្លួនតាមវិធាន៣៥នៃវិធានផ្ទៃក្នុងនោះ មេធាវីការពារក្តីរបស់ អៀង សារី ត្រូវតែបង្ហាញឱ្យឃើញអំពី "មានមូលហេតុដែលធ្វើឱ្យជឿជាក់"ថាបុគ្គលណាម្នាក់ "បានជ្រៀតជ្រែក ដោយបានដឹង និងដោយចេតនា ចូលនៅក្នុងកិច្ចការគ្រប់គ្រងរដ្ឋបាលរបស់តុលាការ"។ ដើម្បីរកឱ្យឃើញថា បទដ្ឋានស្តីពី "មានមូលហេតុដែលធ្វើឱ្យជឿជាក់"ត្រូវបានបំពេញសព្វគ្រប់នោះ អង្គជំនុំជម្រះត្រូវតែរកឱ្យឃើញថា "មានមូលដ្ឋានខាងសម្ភារៈ ឬមានមូលហេតុណាមួយដែលជាមូលដ្ឋានគ្រឹះនៃជំនឿជឿជាក់របស់ពួកគេ"[32]។ មូលដ្ឋានខាងសម្ភារៈ មិនមែនជាការស្មាននោះទេ ត្រូវតែគាំទ្រដល់ធាតុផ្សំខាងសម្ភារៈទាំងពីរដែលបានចោទប្រកាន់ ឬដល់*អំពើពិរុទ្ធណាមួយ* គឺមានន័យថា "ការជ្រៀតជ្រែកចូលនៅក្នុងកិច្ចការគ្រប់គ្រងរដ្ឋបាលរបស់តុលាការ" និងមានការចោទប្រកាន់ពីធាតុផ្សំខាងស្មារតី ឬមាន*បំណងឧក្រិដ្ឋ* គឺថា "ដោយចេតនា ឬដោយបានដឹង"។ ខ្លឹមសារនៃពាក្យ "កិច្ចការគ្រប់គ្រងរដ្ឋបាលតុលាការ" ដែលនៅក្នុងវិធាន៣៥នៃវិធានផ្ទៃក្នុង គឺទាក់ទងតែទៅនឹងបញ្ហានានា "ដែលពាក់ព័ន្ធគ្នាយ៉ាងជិតស្និទ្ធជាមួយនឹងការប្រព្រឹត្តិទៅនៃដំណើរការនីតិវិធីរបស់តុលាការនៅចំពោះមុខតុលាការនេះតែប៉ុណ្ណោះ"[33]។

ឆន្ទានុសិទ្ធិរបស់ខ្លួន ថាតើត្រូវធ្វើការផ្តួចផ្តើមគំនិតដើម្បីបន្តដំណើរការនីតិវិធីតទៅទៀតដែរ ឬក៏អត់? អាស្រ័យហេតុនេះ មិនមានអង្គសេចក្តីដើម្បីឱ្យការតវ៉ាជំទាស់របស់ Nshogoza ថា បន្ទាប់ពីរកឃើញមានហេតុផលគ្រប់គ្រាន់ ដើម្បីដំណើរការ ឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងករណីរឿងនេះ ត្រូវបានកម្រិតមកនៅត្រឹមការបង្គាប់ឱ្យធ្វើការស៊ើបអង្កេតមួយក៏ធ្វើការចោទប្រកាន់ចំពោះសាមាជិករបស់អយ្យការ"។ (ការលើកឡើងនូវសំអាងផ្ទៃក្នុងត្រូវបានលុប)។

[31] **D137/5** សេចក្តីសម្រេច កំណត់សំគាល់លេខ៦ ត្រង់កថាខណ្ឌទី១៩។

[32] ឯកសារលេខ **D314/1/12** *សេចក្តីសម្រេចលើកទី២ លើបណ្តឹងសាទុក្ខរបស់ នួន ជា និង អៀង សារី ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំឱ្យកោះហៅសាក្សីនានា*, ចុះថ្ងៃទី៩ កញ្ញា ២០១០, កថាខណ្ឌទី៣៧ ("សេចក្តីសម្រេចលើកទី២")។

[33] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Milošević*, សំណុំរឿងលេខ IT-02-54-Misc5 និងលេខ IT-02-54-Misc6, *សេចក្តីសម្រេចស្តីពីការផ្តួចផ្តើមគំនិតដើម្បីធ្វើការស៊ើបអង្កេតអំពីការប្រមាថមើលងាយ*, ចុះថ្ងៃទី១៨ កក្កដា ២០១១ , កថាខណ្ឌទី១១។ អវតក បានកត់សំគាល់

១៩- សំណើនេះមិនបានបង្ហាញឲ្យឃើញពី *មូលដ្ឋានខាងភស្តុតាងណាមួយ* ដែលគាំទ្រចំពោះហេតុផលសម្រាប់ធ្វើការស៊ើបអង្កេតឡើយ។ គ្មានអ្វីគាំទ្រចំពោះសំណើដែលថាកិច្ចជួបប្រជុំគ្នារវាងលោកស្រីចៅក្រម Cartwright លោក Cayley និង/ឬ លោក Rosenhaug មិនមានទាក់ទងនឹងអ្វីលើសពីបញ្ហារដ្ឋបាល និងបញ្ហាកិច្ចដំណើរការនោះឡើយ ដូចដែលមានការពន្យល់បន្ថែមនៅក្នុងផ្នែកទី III(គ)(i)ខាងក្រោមនេះ ដែលអាចឲ្យទទួលយកបាននៅក្នុងបរិបទជាតុលាការឧក្រិដ្ឋកម្មមួយដែលធ្វើជាអន្តរជាតូបនីយកម្ម។ ជាលទ្ធផល គេខកខានមិនបានផ្តល់នូវមូលដ្ឋានសម្ភារៈណាមួយដើម្បីចង្អុលបង្ហាញភស្តុតាងអំពីធាតុផ្សំខាងសម្ភារៈ ដែលមានន័យថា កិច្ចប្រជុំរដ្ឋបាលទាំងនេះបង្កើតបានជាការជ្រៀតជ្រែកចូលក្នុងកិច្ចការគ្រប់គ្រងរដ្ឋបាលរបស់តុលាការចំពោះ អៀង សារី នៅក្នុងសំណុំរឿងលេខ០០២នោះឡើយ។ មេធាវីការពារក្តីរបស់ អៀង សារី ក៏*មិនបាន*ទាញហេតុផលដែរថា ការអះអាងអំពីមានការជ្រៀតជ្រែកណាមួយចូលក្នុងកិច្ចការគ្រប់គ្រងរដ្ឋបាលរបស់តុលាការ ត្រូវបានធ្វើឡើង ដោយតម្រូវឲ្យមានធាតុផ្សំខាងស្មារតី[34] នោះមានន័យថាគឺថាការប្រជុំត្រូវបានធ្វើឡើងដោយបានដឹងថាជាការពិភាក្សាអំពីបញ្ហានានាខាងរដ្ឋបាល គឺជាការជ្រៀតជ្រែកមួយចូលនៅក្នុងកិច្ចការគ្រប់គ្រងរដ្ឋបាលរបស់តុលាការ និងដោយមានចេតនាប្រព្រឹត្តបំពានចំពោះគោលការណ៍នេះ[35]។

២០- នៅពេលដែលបណ្តឹងសាទុក្ខខំព្យាយាមប្រើល្បិច តាមរយៈការយោងទៅលិខិតផ្លូវការនានាដែលបានបញ្ជូនទៅ និងទៅលើសារណាជាលាយលក្ខណ៍អក្សរដែលធ្វើឡើងដោយក្រុមមេធាវីការពារក្តីរបស់

អំពីភាពស្រដៀងគ្នានៃវិធាន៣៥ និងវិធាន៧៧ នៃវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICTY, និងបានរកឃើញថាការបកស្រាយនៃវិធាន៧៧ មានលក្ខណៈបកស្រាយ។ ឯកសារលេខ **D314/1/12** សេចក្តីសម្រេចលើកទី២, កំណត់សំគាល់លេខ៣១ ខាងដើម ត្រង់កថាខណ្ឌទី៣១, ៣២។

[34] ពួកគេបានបញ្ជាក់អំពីបទដ្ឋានស្តីពី*ចេតនាឧក្រិដ្ឋ* តែនៅក្នុងពេលដកស្រង់ខ្លឹមសារពីលិខិតមួយដែលពួកគេបានសរសេរថា មិនត្រូវបានដាក់មកតាមទម្រង់ការ ហើយខ្លឹមសារសំខាន់នៃសំណើដែលត្រូវបានបដិសេធ។ ឯកសារលេខ **E137/5/1/1** បណ្តឹងសាទុក្ខ, កំណត់សំគាល់លេខ៩ ខាងដើម ត្រង់កថាខណ្ឌទី២៦។

[35] *សូមអាន, ជាទូទៅ, ករណីរឿងក្តីរបស់រដ្ឋអាជ្ញា ទល់នឹង Vojislav Šešelj*, សំណុំរឿងលេខ IT-03-67-R.77.4, ច្បាប់ដែលត្រូវបានពិនិត្យកែសំរួលសម្រាប់ការផ្សាយជូនសាធារណៈជននៃ *"សេចក្តីសម្រេចស្តីពីការខកខានក្នុងការដកនូវព័ត៌មានសម្ងាត់ចេញពីគេហទំព័រសារធារណៈ និង ដីកាសម្រេចជំនួសឲ្យដីកាបញ្ជូនរឿងទៅជំនុំជម្រះ" ដែលបានចេញកាលពីថ្ងៃទី ៩ ឧសភា ២០១១*, ចុះថ្ងៃទី២៤ ឧសភា ២០១១ ត្រង់កថាខណ្ឌទី២៧ ។ *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Milošević*, សំណុំរឿងលេខ IT-02-54-A-R77.4, *សេចក្តីសម្រេចលើបណ្តឹងសាទុក្ខលើបញ្ហាបន្ទាន់បង្ខំស្តីពីដំណើការរឿងក្តីលើករណីប្រមាថមើលងាយរបស់ Kosta Bulatović*, ចុះថ្ងៃទី២៩ សីហា ២០០៥ ត្រង់កថាខណ្ឌពីទី៤០-៤៣។

អៀង សារី និង នួន ជា និងសេចក្តីថ្លែងការណ៍ផ្សេងៗ នៅក្នុងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាននោះ គឺវាមិនអាចស្មើនឹង "មានមូលហេតុដែលធ្វើឱ្យជឿជាក់" ដែលតម្រូវដោយវិធាន៣៥នៃវិធានផ្ទៃក្នុងបានទេ។ បណ្តឹងរបស់មេធាវីការពារក្តីរបស់ អៀង សារី ដែលថា សហព្រះរាជអាជ្ញា Andrew Cayley និងអ្នកផ្សេងៗទៀត មិនបានឆ្លើយតបជាអន្លើៗទៅនឹងលិខិតឆ្លើយឆ្លងមុនៗរបស់ អៀង សារី លើបញ្ហានេះ គឺជាការបំពេញគ្រប់សព្វចំពោះបទដ្ឋាននោះហើយ។ បើសិនជាអ្វីៗត្រូវបំពេញគ្រប់គ្រាន់ ភាគី ឬចៅក្រមណាម្នាក់ដែលមិនបានធ្វើការឆ្លើយតបទៅនឹងសំណើដែលឥតបានការណាមួយ អាចនឹងត្រូវបានធ្វើការស៊ើបអង្កេត។

២១- លក្ខខណ្ឌស្តីពីកម្រិតនៃភស្តុតាងដូចមានចែងក្នុងវិធាន៣៥ គឺជាយន្តការសម្រាប់ច្រោះដ៏សមស្របមួយ ដើម្បីទប់ស្កាត់ការប្រើប្រាស់មិនត្រឹមត្រូវនូវពេលវេលាតុលាការ និងធនធានដ៏អត្ថខាត់ ក្នុងការលើកថ្លែងអំពីបណ្តឹងនានាដែលគ្មានមូលដ្ឋានច្បាស់លាស់ និងគ្មានន័យខ្លឹមសារ។ ការណ៍នេះ គឺស៊ីសង្វាក់គ្នាទាំងស្រុងទៅនឹងគំរូដែលបានអនុម័តដោយវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ និងនិយ័តកម្មបន្ទាប់បន្សំរបស់ខ្លួនផ្សេងៗទៀត ក្នុងការដោះស្រាយនូវបណ្តឹងនានាស្តីពីអំពើប្រព្រឹត្តមិនត្រឹមត្រូវប្រឆាំងនឹងចៅក្រម ឬព្រះរាជអាជ្ញាណាម្នាក់។ អត្ថបទច្បាប់ទាំងនេះបង្គាប់ឱ្យអ្នកកាន់តំណែងជាប្រធាន ធ្វើការវាយតម្លៃជាបឋម និងទុកមួយអន្លើនូវពាក្យបណ្តឹងទាំងឡាយណាដែល "មានលក្ខណៈអនាមិក ឬគ្មានមូលដ្ឋានជាក់ស្តែង"[36] ដោយពុំចាំបាច់ឱ្យមានការពិចារណាអ្វីបន្ថែមទៀតឡើយ។ តុលាការសិទ្ធិមនុស្សអឺរ៉ុប គណៈកម្មការអន្តរអាមេរិកកាំងស្តីពីសិទ្ធិមនុស្ស និងគណៈកម្មាធិការប្រឆាំងការធ្វើទារុណកម្ម - ដែលយុត្តាធិការមានលក្ខណៈរសើបចំពោះទំនាក់ទំនងនៃអំណាចមិនស្មើគ្នារវាងអ្នកប្តឹង និងអាជ្ញាធររដ្ឋ - អះអាងថា ពាក្យបណ្តឹងមួយនឹងទៅជា "គ្មានភស្តុតាងត្រឹមត្រូវជាក់ស្តែង" ឬ "គ្មានមូលដ្ឋានជាក់ស្តែង" និងថា *បើដូច្នេះមិនអាចទទួលយកបាន* បើសិនជាបណ្តឹងនោះខកខានមិនបានបង្ហាញយ៉ាងហោចណាស់នូវ *មូលដ្ឋាននៃភស្តុតាងមួយក្រឡេកម្នែក* ឬបានពឹងផ្អែកទៅលើតែការស្មាន[37]។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា

[36] វិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICC, វិធាន២៦(២); បទបញ្ជារបស់តុលាការ ICC, បទបញ្ជាលេខ ១២០-១២១។

[37] សម្រាប់តុលាការ ECHR, សូមអាន: *Gomes ទល់នឹង ប្រទេសស៊ុយអែត* (សេចក្តីសម្រេចស្តីពីភាពអាចទទួលយកបាន, ពាក្យសុំលេខ 34566/04, ៧ កុម្ភៈ ២០០៦) ត្រង់ទំព័រទី១១ (តម្រូវឱ្យមានភស្តុតាងសំខាន់ៗដែលអាចជឿជាក់បាន" ដើម្បីយកជាកម្រិតកំពូលសម្រាប់ភាពអាចទទួលយកបាន; សម្រាប់ IACHR, សូមអាន: *Monsi Lilia Velarde Retamozo ទល់នឹង ប្រទេសប៉េរូ,* សំណុំរឿងលេខ 12.165, របាយការណ៍លេខ 85/03, អន្តរអាមេរិកកាំង C.H.R., OEA/Ser.L/V/II.118 ឯកសារ70 វិសោធនកម្មទី 2 ត្រង់ 437 (២០០៣) ត្រង់កថាខណ្ឌទី៤៥; សូមអានផងដែរ *V. ទល់នឹង ប្រទេសបូលីវៀរ,* សំណុំរឿងលេខ 270-07, របាយការណ៍លេខ 40/08,

អង្គជំនុំជម្រះគួរអនុវត្តឱ្យបានត្រឹមត្រូវនូវបទដ្ឋានស្រដៀងគ្នានេះ ក្នុងការដោះស្រាយបញ្ចប់បណ្ដឹងសាទុក្ខនេះ។

### *i. ចរិកលក្ខណៈសមស្របនៃការប្រាស្រ័យទាក់ទង*

២២- អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ការប្រាស្រ័យទាក់ទងគ្នាខ្លះ រវាងអនុប្រធាន ព្រះរាជអាជ្ញា និង/ឬ អនុប្រធានរដ្ឋបាល គឺជាការចាំបាច់ និងសមស្របនៅក្នុងបរិបទនៃតុលាការព្រហ្មទណ្ឌអន្តរតូបនីយកម្ម។ នៅក្នុងតុលាការព្រហ្មទណ្ឌអន្តរតូបនីយកម្មដូចជា អ.វ.ត.ក ជាដើម តួនាទីរបស់សហព្រះរាជអាជ្ញាអន្តរជាតិ - ដែលជាមន្ត្រីជាន់ខ្ពស់នៃអង្គការសហប្រជាជាតិមួយរូប, មិនមែនគ្រាន់តែជាភាគីមួយនៃកិច្ចដំណើរការនីតិវិធីប៉ុណ្ណោះទេ[38]។

២៣- សហព្រះរាជអាជ្ញាអន្តរជាតិ មានការទទួលខុសត្រូវសំខាន់ៗចំពោះកិច្ចការរដ្ឋបាល ដែលមានលក្ខណៈមិនមែនតុលាការ ដែលការទទួលខុសត្រូវទាំងនេះ មានវិសាលភាព *ក្នុងចំណោមកិច្ចការផ្សេងទៀត* ដូចជា ការងារគ្រប់គ្រង ការផ្ដល់យោបល់ ការផ្ទេរចំណេះដឹង និងការកសាងសមត្ថភាពថវិកា បុគ្គលិក ការធ្វើទំនាក់ទំនងកម្រិតខ្ពស់ជាមួយមន្ត្រីជាន់ខ្ពស់អង្គការសហប្រជាជាតិ អ្នកការទូតឥស្សរជន និងបណ្ដារដ្ឋម្ចាស់ជំនួយ ការធ្វើអន្តរសកម្មភាពជាមួយទីភ្នាក់ងារអង្គការសហប្រជាជាតិដទៃទៀតនៅកម្ពុជា និងក្នុងតំបន់ និងដោយរួមជាមួយសហព្រះរាជអាជ្ញាជាតិ ធានាឱ្យប្រាកដថាការិយាល័យសហព្រះរាជអាជ្ញាមានធនធានចាំបាច់ មានការគាំទ្រខាងផ្នែកភស្តុភារ និងរដ្ឋបាលដើម្បីបង្កលទ្ធភាពឱ្យខ្លួនបំពេញនូវការទទួលខុសត្រូវរបស់ខ្លួនបានស្របទៅតាមច្បាប់។ មិនមាន

---

អន្តរអាមេរិកកាំង C.H.R., OEA/Ser.L/V/II.130 ឯកសារ 22, វិសោធនកម្មទី 1 (២០០៨) ត្រង់កថាខណ្ឌទី 79; *Herrera y Vargas (La Nación)*, ប្រទេសកូស្ដារីកា, សំណុំរឿងលេខ 12,367, ៣ ធ្នូ, IACHR, របាយការណ៍លេខ 128/01, 2001 ត្រង់កថាខណ្ឌទី 50; របាយការណ៍លេខ 4/04, ញត្តិ 12,324, *Rubén Luis Godoy*, ប្រទេសអាហ្សង់ទីន, ២៤ កុម្ភៈ ២០០៤, ត្រង់កថាខណ្ឌទី 43 និង របាយការណ៍លេខ 29/07, ញត្តិ 712-03, *Elena Tellez Blanco*, ប្រទេសកូស្ដារីកា, ២៦ មេសា ២០០៧, ត្រង់កថាខណ្ឌទី 58; សម្រាប់អនុសញ្ញា CAT សូមអាន: អនុសាសន៍ទូទៅលេខ ០១: ការអនុវត្តន៍មាត្រា៣ នៃអនុសញ្ញានេះ ក្នុងបរិបទនៃមាត្រា២២ (11/21/1997. A/53/44, ឧបសម្ព័ន្ធ IX, CAT អនុសាសន៍ទូទៅលេខ ០១: (អនុសាសន៍ទូទៅ) ត្រង់កថាខណ្ឌទី 4-6; 6 *H.I.A. ទល់នឹងប្រទេសស៊ុយអែត*, ការប្រាស្រ័យទាក់ទងលេខ 216/2002, ឯកសារ U.N. CAT/C/30/D/216/2002 (2003) (សេចក្ដីសម្រេចរបស់គណៈកម្មាធិការប្រឆាំងការធ្វើទារុណកម្ម តាមមាត្រា២២ នៃអនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម និងអំពើឃោរឃៅ, អំពើអមនុស្សធម៌ ឬអំពើបន្ទាបបន្ថោក ឬការផ្ដន្ទាទោសដទៃទៀត - សម័យប្រជុំលើកទីសាមសិប - ការប្រាស្រ័យទាក់ទងលេខ 216/2002) ត្រង់កថាខណ្ឌទី 6.1-6.2។

[38] **E137/5** សេចក្ដីសម្រេច, កំណត់សំគាល់*ខាងដើម* លេខ៦ ត្រង់កថាខណ្ឌទី២០។

សហព្រះរាជអាជ្ញាណាម្នាក់បានប្រព្រឹត្តិនៅក្រោមបង្គាប់របស់នីតិបញ្ញត្តិ នីតិប្រតិបត្តិ ឬតុលាការនៃរដ្ឋាភិបាលកម្ពុជាទេ ហើយសហព្រះរាជអាជ្ញាទាំងពីររូបមានអាណត្តិដែលត្រូវបំពេញមុខងាររបស់ខ្លួន ដោយឯករាជ្យ និងមិនទទួល ឬស្វែងរកការបង្គាប់បញ្ជាពីរដ្ឋាភិបាលណាមួយ ឬប្រភពណាមួយផ្សេងទៀតឡើយ[39]។

២៤- មិនមែនមានតែក្រុមវិជ្ជាជីវៈតុលាការរបស់ អ.វ.ត.ក ប៉ុណ្ណោះទេ ដែលមិនហាមឃាត់ការជួបប្រជុំដូច្នេះ[40] សូម្បីតែទម្លាប់នៃការអនុវត្តល្អៗរបស់តុលាការ និងសាលាក្តីអន្តរជាតិ និងអន្តរតួបនីយកម្មដទៃទៀត ក៏បង្ហាញឲ្យឃើញអំពីតម្រូវការចាំបាច់នូវយន្តការផ្សេងៗ ក្នុងការគាំទ្រលើការគ្រប់គ្រងធនធានឲ្យមានប្រសិទ្ធភាព និងដោយប្រុងប្រយ័ត្ន ហើយនិងការសម្របសម្រួលជាយុទ្ធសាស្ត្រកម្រិតខ្ពស់រវាងអាជ្ញាធរដែលទទួលខុសត្រូវចំពោះការជំនុំជម្រះក្តី ការចោទប្រកាន់ និងការគ្រប់គ្រងផ្នែករដ្ឋបាល។ ការសម្របសម្រួលដូច្នេះ គឺខុសគ្នាទាំងគំនិត និងទាំងការអនុវត្តពីបរិបទនៃ "ដំណើរការរបស់ អ.វ.ត.ក" ដែលមានវិធានជាអ្នក "ធានាចំពោះភាពដាច់ពីគ្នា" រវាងការចោទប្រកាន់ និងការជំនុំជម្រះក្តី[41]។ ដូចសហព្រះរាជអាជ្ញាអន្តរជាតិលោក ឃេលី បានមានប្រសាសន៍ថា បើសិនជាគ្មានការជួបប្រជុំដូច្នេះទេ "ម្ល៉េះស្ថាប័នទាំងនេះ រួមទាំង អ.វ.ត.ក ផង នឹងត្រូវខ្វិនមិនអាចធ្វើអ្វីកើតឡើយ"[42]។

២៥- ឧទាហរណ៍ ចាប់ពីឆ្នាំ២០០១មក តុលាការ ICTY បានដាក់បន្ថែមក្នុងការិយាល័យរបស់ខ្លួន[43]ទាំងគណៈកម្មាធិការគ្រប់គ្រងមួយ[44] - ដែលមានរចនាសម្ព័ន្ធ និងមុខងារអាចប្រៀបធៀបបាននឹងគណៈកម្មាធិការគ្រប់គ្រងរដ្ឋបាលតុលាការរបស់ អ.វ.ត.ក ("JAC") ដែរ ដែលបានលើកយោងនៅក្នុងបណ្តឹងជំទាស់ចិត្ត - *ព្រមទាំង* ក្រុមប្រឹក្សាសម្របសម្រួលមួយ[45] ដែលប្រធាន រដ្ឋអាជ្ញា និងមន្ត្រីរដ្ឋបាល សម្របសម្រួលលើ "សកម្មភាពផ្សេងៗ" របស់ស្ថាប័នទាំងបី "ដើម្បីសម្រេចបាន

---

[39] ច្បាប់ អ.វ.ត.ក, មាត្រា១៩; កិច្ចព្រមព្រៀង, មាត្រា៦(៣)។

[40] ក្រមវិជ្ជាជីវៈតុលាការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, មាត្រា១ & ២។

[41] វិធាន២១(១)(ក)។

[42] Julia Wallace, មេធាវីការពារក្តីនៅសាលាក្តីខ្មែរក្រហម ចោទប្រកាន់អំពីការជួបប្រជុំភាគីតែម្ខាង, Cambodia Daily, ៧ វិច្ឆិកា ២០១១, ទំព័រទី២។

[43] វិធានស្តីពីនីតិវិធី និងភ័ស្តុតាងរបស់តុលាការ ICTY, វិធាន២៣។

[44] វិធានស្តីពីនីតិវិធី និងភ័ស្តុតាងរបស់តុលាការ ICTY, វិធាន២៣*ស្ទួនពីរ*។

[45] វិធានស្តីពីនីតិវិធី និងភ័ស្តុតាងរបស់តុលាការ ICTY, វិធាន២៣*ស្ទួន*។

បេសកកម្មរបស់សាលាក្តី”[46]។ ការងាររបស់ក្រុមប្រឹក្សាសម្របសម្រួល គឺការយកចិត្តទុកដាក់ឲ្យបានសមស្របអំពី “ការទទួលខុសត្រូវ និងឯករាជ្យភាព” នៃសមាជិករបស់ខ្លួន[47]។ រចនាសម្ព័ន្ធជាតួរយ៉ាងនេះក៏ធ្វើប្រតិបត្តិការនៅតុលាការ ICTR[48]។ នៅតុលាការ ICC ក៏បានអនុម័តយកតាមគំរូរបស់ក្រុមប្រឹក្សាសម្របសម្រួលនេះដែរ។ នៅក្នុងសាលាក្តីនិមួយៗ មេធាវីការពារក្តីគ្មានតួនាទីណាមួយ ក្នុងផ្នែកនៃក្រុមប្រឹក្សាសម្របសម្រួលនេះទេ ហើយកំណត់ហេតុនៃកិច្ចប្រជុំនានាក៏មិនត្រូវបានធ្វើឲ្យទៅជាសាធារណៈដែរ[49]។

២៦- ចរិកលក្ខណៈកូនកាត់ និងទំហំវិសាលភាពដ៏ស័ក្តិសិទ្ធិ និងជាទីពេញចិត្តរបស់ អ.វ.ត.ក ជាពិសេសដំណើរសាយភាពនៃមុខងារមន្ត្រីរដ្ឋបាល អាចនឹងមិនអនុញ្ញាតឲ្យមានការចម្លងតាមគ្រប់រចនាសម្ព័ន្ធផ្លូវការទាំងអស់ដែលមាននៅក្នុងសាលាក្តី *មិនអចិន្ត្រៃយ៍* និងតុលាការ ICC[50] នោះទេ។ ប៉ុន្តែ ការណ៍នេះមិនបានដកហូតនូវតម្រូវការឲ្យមានការសម្របសម្រួលរវាងចៅក្រម Cartwright - ដែលជាអនុប្រធាននៃកិច្ចប្រជុំពេញអង្គ និងជាមន្ត្រីតុលាការអន្តរជាតិជាន់ខ្ពស់មួយរូបដ៏មានបទពិសោធន៍- ជាមួយសហព្រះរាជអាជ្ញាអន្តរជាតិ និង/ឬអនុប្រធានរដ្ឋបាល ដែលជាអ្នកមានការទទួលខុសត្រូវដ៏សំខាន់ជាក់លាក់ចំពោះបុគ្គលិកអន្តរជាតិ តាមមាត្រា៣១ថ្មី នៃច្បាប់ អ.វ.ត.ក។ ការណ៍នេះមិនមែនជារឿងប្រទូសរ៉ាយ និងក៏មិនខុសច្បាប់ដែរ។ ផ្ទុយទៅវិញ កិច្ចការទាំងឡាយដែលបានលើកមកពិភាក្សានៅក្នុងកិច្ចប្រជុំរដ្ឋបាលក្រៅផ្លូវការទាំងនេះ គឺទាក់ទងនឹងវិសាលភាពនៃបញ្ហាប្រតិបត្តិការដែលប៉ះពាល់សាលាក្តីអន្តរតុលាការ មិនពាក់ព័ន្ធនឹង“កិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក” ទេ និងកាន់តែតិចបំផុតទៅនឹងជនជាប់ចោទជាក់លាក់ណាម្នាក់នោះ។ លើសពីនេះទៀត នៅក្នុងវិធានផ្ទៃក្នុង គ្មានអ្វីទាំងអស់ដែលហាមឃាត់មិនឲ្យមានកិច្ចប្រជុំរដ្ឋបាល និងក៏គ្មានអ្វីដែលចែង

---

[46] *ក្នុងឯកសារដដែល*។

[47] *ក្នុងឯកសារដដែល*។

[48] វិធានស្តីពីនីតិវិធី និងភ័ស្តុតាងរបស់តុលាការ ICTR, វិធាន២៣, វិធាន២៣*ស្ទួន* និងវិធាន២៣*ស្ទួនពីរ*។

[49] មេធាវីការពារក្តី អៀង សារី អះអាងថា “ប្រធាន [sic] តុលាការ ICTY, ICTR និង ICC មិនមែនជាសមាសភាពក្នុងអង្គជំនុំជម្រះក្នុងរឿងក្តី ដែលរដ្ឋអាជ្ញារូបនោះធ្លាប់មានវត្តមាន និងបន្តមានវត្តមាននៅចំពោះមុខប្រធានតុលាការទាំងនោះឡើយ” គឺជាក់ស្តែងណាស់ជាការមិនត្រូវ។ បណ្តឹងសាទុក្ខ, កំណត់សំគាល់*ខាងដើម* លេខ៩ ត្រង់កថាខណ្ឌទី៣៦។ នៅគ្រប់ស្ថាប័នទាំងបីនៃស្ថាប័នតុលាការទាំងអស់នេះ ប្រធានគឺជាចៅក្រមសកម្មដែលមានវត្តមាននៅក្នុងអង្គជំនុំជម្រះក្នុងរឿងក្តីនានាដែលក្នុងនោះរដ្ឋអាជ្ញា គឺជាភាគីមួយ។

[50] អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានកត់សំគាល់ពីមុនថា “អ.វ.ត.ក មានលក្ខណៈជាច្រើនដែលខុសគ្នាពីបណ្តាតុលាការ និងសាលាក្តីអន្តរតូបនីយកម្មដទៃទៀត”។ **E5/3** *សេចក្តីសម្រេចលើបណ្តឹងរបស់ អៀង សារី ដែលប្តឹងជំទាស់ចិត្តចំពោះលោកចៅក្រម និល ណុន និងសំណើពាក់ព័ន្ធផ្សេងៗ*, ២៨ មករា ២០១១ ត្រង់កថាខណ្ឌទី១៤ ។

កំណត់ថាគណៈកម្មាធិការ JAC គឺជាយន្តការផ្តាច់មុខសម្រាប់ការធ្វើដូច្នេះ ដូចដែលមេធាវីការពារក្តី អៀង សារី បានអះអាង។ ដូចអង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា: “ប្រធានទាំងអស់មានការទទួលខុសត្រូវដែលមិនពាក់ព័ន្ធនឹងតុលាការ និងការទទួលខុសត្រូវផ្នែករដ្ឋបាលដ៏សំខាន់ ដែលមានវិសាលភាព*ក្នុងចំណោមកិច្ចការផ្សេងទៀត* ដូចជា ការងារគ្រប់គ្រង ការផ្តល់យោបល់ ថវិកា ការចាត់ចែងបុគ្គលិក និងទំនាក់ទំនងកម្រិតខ្ពស់ជាមួយមន្ត្រីជាន់ខ្ពស់អង្គការសហប្រជាជាតិ អ្នកការទូត ឥស្សរជន និងបណ្តារដ្ឋម្ចាស់ជំនួយ។ មុខងារទាំងនេះ គឺជាការចាំបាច់ ដើម្បីធានាខាងផ្នែកអន្តរជាតិនៃ អ.វ.ត.ក មានធនធានចាំបាច់ និងការគាំទ្រផ្នែកភ័ស្តុភារ និងរដ្ឋបាល ដើម្បីបំពេញអាណត្តិរបស់ខ្លួន”[51]។

២៧- អាស្រ័យហេតុនេះ សូម្បីតែពិចារណាដូចសេចក្តីសន្និដ្ឋានអនុលោមតាមវិធាន៣៥ក៏ដោយ ក៏មេធាវីការពារក្តី អៀង សារី ខកខានមិនបានបំពេញទៅតាមបន្ទុករបស់ខ្លួនដែរ ហើយបណ្តឹងសាទុក្ខនេះគួរតែត្រូវបានបដិសេធចោល។

## IV. ដំណោះស្រាយដែលបានស្នើសុំ

២៨- ដោយមូលហេតុទាំងនេះ សហព្រះរាជអាជ្ញាសូមស្នើអង្គជំនុំជម្រះតុលាការកំពូល ដូចតទៅ ៖

ក. ច្រានចោលបណ្តឹងសាទុក្ខ ដោយសារមិនអាចទទួលយកបាន និងគ្មានមូលដ្ឋានជាក់ស្តែង ដោយហេតុថា៖

១) បណ្តឹងសាទុក្ខនេះគ្មានពាក់ព័ន្ធនឹងបញ្ហាដែលជាកម្មវត្ថុនៃបណ្តឹងសាទុក្ខភ្លាមៗ ដូចមានចែងក្នុងវិធាន ១០៤(៤) ហើយ

២) បណ្តឹងសាទុក្ខនេះខកខានមិនបានបង្ហាញឱ្យឃើញ *ភ័ស្តុតាងមួយក្រឡេកមើល*ដើម្បីជាយុត្តិកម្មសម្រាប់ឱ្យមានកិច្ចស៊ើបសួរណាមួយ តាមវិធាន៣៥; ឬ

[51] **E137/5** សេចក្តីសម្រេច, កំណត់សំគាល់*ខាងដើម*លេខ៦ ត្រង់កថាខណ្ឌទី២០។

ខ. បដិសេធចោលបណ្តឹងសាទុក្ខនេះ ដោយសារៈ

១) អង្គជំនុំជម្រះសាលាដំបូងមិនបានរំលោភឆន្ទានុសិទ្ធិរបស់ខ្លួន; និង

២) សំណើ និងបណ្តឹងសាទុក្ខនេះ ខកខានមិនបានផ្តល់បន្ទុករបស់ខ្លួន ដើម្បីធ្វើយុត្តិកម្ម សម្រាប់កិច្ចស៊ើបសួរណាមួយស្របតាមវិធាន៣៥ ទេ។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១២ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក** William SMITH<br>សហព្រះរាជអាជ្ញារង | | [signature] |